## ដង្កូវស៊ីបណ្តូលស្ពៃក្តោប

កូនដង្កូវស៊ីត្រួយខ្ចីចោះចូលទៅក្នុងបណ្តូល និងផ្នែកខាងក្រៅក្តោប។ ដង្កូវនេះបានបំផ្លាញត្រួយបណ្តូលនៃក្តោបបង្កឱ្យស្ពៃមិនអាចក្តោបបាន ។ សំបុករបស់វាស្ថិតនៅផ្នែកខាងលើនៃស្លឹកខាងក្នុង។

យើងត្រូវការពារស្ពៃក្តោបបានយ៉ាងហោចណាស់ឱ្យបានមួយខែបន្ទាប់ពីបានដាំកូនហើយ ។ ដោយសារដង្កូវនេះបំផ្លាញបណ្តូលស្ពៃក្តោបខ្លាំងក្លាបំផុតនៅក្នុងដំណាក់កាលនេះ ។



## ដង្កូវស៊ីត្រួយស្ពៃក្តោប



ដង្កូវស៊ីចោះផ្ទៃស្លឹកខាងក្រៅ ហើយស៊ីរូងចូលក្នុងធ្វើឱ្យស្ពៃមិនអាចក្តោបបាន។ កញ្ចុំសំបុកពងរបស់វាងាយរកឃើញនៅលើផ្ទៃស្លឹកផ្នែកខាងក្រោមដើម។

## ដង្កូវយោលទោង

កូនដង្កូវទើបនិងញាស់ វាចាប់ផ្តើមស៊ីបកយក ជាលិកាបៃតង ផ្នែកខាងក្រោមស្លឹកខ្ចីៗ ដោយបន្សល់ទុកសរសៃស្តើងៗផ្នែកខាងលើ។ ដង្កូវនេះបញ្ចប់ការស៊ីរបស់វារហូតក្លាយជាឌឹកឌឿ។



## ដង្កូវចោះផ្លែប៉េងប៉ោះ

ដង្កូវទើបញាស់តូចៗស៊ីជាលិកាស្លឹកខ្ចីៗ ។ ឯដង្កូវពេញវ័យស៊ីដាច់ស្លឹកខ្ចីបង្កើតបានជាប្រហោងរុនតូចធំ រួចចោះចូលទៅក្នុងផ្លែធ្វើឱ្យប៉េងប៉ោះស្អុយរលួយ ។ ចំពោះដង្កូវវ័យចំណាស់វាចាប់ផ្តើមស៊ីបំផ្លាញចំនុច លូតលាស់ដូចជា កញ្ចុំផ្កា ផ្កា និងក្តិប។

ការការពារដង្កូវនេះត្រូវកាត់មែកស្លឹកមួយចំនួនចោលដោតចំណារចងដើមឱ្យស្រឡះពីដី។ ការប្រើថ្នាំពុលកសិកម្មមានប្រសិទ្ធភាព គឺនៅពេលសត្វល្អិតទើបញាស់ (កូនដង្កូវ) និងបេះផ្លែមានដង្កូវស៊ីចេញជាមុនសិន។



## ដង្កូវចោះផ្លែ និង ដង្កូវស៊ីរូងដើមត្រប់

មេអំបៅតែងពងដាក់ផ្នែកខាងក្រោមស្លឹក លើផ្កា និងដើមជារាយៗ ឬជាក្រុម។ ក្រោយមកពងវាញាស់ជាដង្កូវហើយចោះចូលក្នុងដើមផ្នែកខ្ចីនៃត្រួយធ្វើឱ្យត្រួយ នៃដំណាំត្រប់ស្រពោនមិន អាចលូតលាស់បាន ឬចោះចូលក្នុងក្តិបខ្ចីៗ ធ្វើឱ្យផ្លែស្អុយរលួយ ។ **ការការពារ**ដង្កូវនេះត្រូវកាត់រំលោះមែក ស្លឹក ត្រួយ ផ្លែដែលមានដង្កូវស៊ីចោល និងសំអាតស្មៅ ព្រមទាំងប្រើថ្នាំពុលកសិកម្មនៅពេលសត្វល្អិតទើបញាស់(កូនដង្កូវ)។



## ដង្កូវស៊ីរូងកួរសណ្តែក

ដង្កូវបញ្ចេញសរសៃសូត្រសម្រាប់មូរកញ្ចុំផ្កាលាយជាមួយនឹងស្លឹកដែលនៅក្បែរនោះ។ បន្ទាប់មកចោះចូលក្នុងផ្កា និងផ្លែ។ ដង្កូវនេះវាចូលចិត្តស៊ីផ្កា ធ្វើឱ្យផ្កាមិនលូតលាស់មិនចេញផ្លែទេ ។តែបើវាស៊ីក្នុងកួរសណ្តែកធ្វើឱ្យកួរសណ្តែកស្អុយដាច់ជាកំណាត់ ។ **ការការពារ** ត្រូវបេះកួរសណ្តែកដែលមានដង្កូវស៊ីហើយបំផ្លាញវាចោល និងប្រមូលដើមសណ្តែកបន្ទាប់ពីប្រមូលផលហើយដុតចោលដើម្បីការពារការកើនបរិមាណដង្កូវជំនាន់ក្រោយ ។



## ដង្កូវហ្វូង

ដង្កូវហ្វូងស៊ីស្លឹក ដើមនឹងផ្លែរបស់បន្លែជាច្រើនប្រភេទ។ វាស៊ីស្លឹកយ៉ាងធ្ងន់ធ្ងរជាពិសេសនៅ ដំណាក់កាលកូនបន្លែកំពុងលូតលាស់ ។ ដង្កូវចំណាស់វាស៊ីបំផ្លាញស្លឹកនៅពេលយប់ ។ នៅពេលថ្ងៃយើងអាចរកឃើញពួកវាលាក់ខ្លួនក្នុងចំនុចកណ្តាលនៃក្រោមស្លឹកឬនៅជុំវិញគល់ដំណាំ ។ ការការពារត្រូវគ្របថ្នាលបណ្តុះកូនដំណាំដោយសំណាញ់ការពារសត្វល្អិតនិងបេះដង្កូវដោយដៃហើយញេចវាចោល ។



### វិធានការកំចាត់តាមវិធីដាំដុះ

- ប្រើសំណាញ់សត្វល្អិតដើម្បីគ្របការពារថ្នាលបណ្ដុះកូនបន្លែ ។
- បណ្ដុះកូនដំណាំឱ្យឆ្ងាយពីចំការកំពុងដាំបន្លែ ។
- បេះដង្កូវដោយដៃហើយញេចវាចោល ។
- បេះផ្លែដែលមានដង្កូវស៊ីយកទៅកប់ឱ្យបានជំរៅ ២០ ស.ម ។
- រដូវត្រជាក់ និងភ្លៀងត្រូវដាំឱ្យរង្វើលជាងរដូវក្ដៅ ។
- សំអាតសៅនៅក្នុងចំការ ។
- ដាំដំណាំឆ្លាស់ជៀសវាងដាំដំណាំដដែលៗអាចកាត់បន្ថយ សត្វល្អិតមួយចំនួនដែលរស់នៅ ក្នុងដីសល់ពីរដូវមុន ។
- ប្រមូលកំទេចកំទីបន្ទាប់ពីប្រមូលផលហើយចេញពីចំការ ។

### វិធានការគីមីប្រើសម្រាប់កំចាត់ពពួកដង្កូវមេអំបៅ

- ដំណាំបន្លែយកផ្លែ (ម្ទេស ត្រប់ សណ្ដែកកួរ ប៉េងប៉ោះ ត្រសក់ ) ដំណាំទាំងនេះត្រូវបាញ់នៅក្នុង ដំណាក់កាលលូតលាស់រហូតដល់ចេញផ្កា ។
- ការបាញ់ថ្នាំពុលកសិកម្ម គឺធ្វើឡើងពីក្រោមនិងលើស្លឹក

### ថ្នាំគីមីដែលអាចប្រើប្រាស់បានមានដូចជា:

- បាក់ស៊ីលូស ស្សូរីនជៀនស៊ីស (Bacillus thuringiensis)
- ថ្នាំបេតា ស៊ីហ្វូស្រីន ( Beta-cyfluthrin)
- ថ្នាំក្លូភីរីហ្វូស ( Chlorpirifos )
- ថ្នាំស៊ីភើមេទ្រីន ( Cypermethrin )

**ការកំចាត់តាមវិធានការគីមី** មានប្រសិទ្ធិភាព លុះត្រាតែអនុវត្តវិធានការកំចាត់ តាមវិធីដាំដុះជាមុនសិន ។

### សូមរក្សាការរង់ចាំនៃរយៈពេលរង់ចាំ

ដើម្បីបានបន្លែបរិភោគដោយសុវត្ថិភាព ការប្រមូលផល ត្រូវរង់ចាំយ៉ាងតិច ៧ ថ្ងៃ បន្ទាប់ពីបាញ់ថ្នាំ ។

### សុវត្ថិភាពការប្រើប្រាស់ថ្នាំកសិកម្ម

ត្រូវពាក់សម្ភារៈការពារ នៅពេលលាយថ្នាំ និង បាញ់ថ្នាំកសិកម្មដូចជា:

- ម៉ាស់ការពារផ្លូវដង្ហើម និង វ៉ែនតា
- ស្រោមដៃ ស្បែកជើងកវែង និង មួក
- អាវដៃវែង ខោជើងវែង (ជាការប្រសើរបើវាមិនជ្រាប ទឹកទៀតនោះ)

### ប្រការត្រូវចងចាំ

- ជៀសវាងបាញ់ថ្នាំនៅពេលដែលមានឃ្មុំកំពុងហើរក្នុងចំការ
- មិនត្រូវលាយ និងបាញ់ថ្នាំនៅពេលមានខ្យល់
- ជៀសវាងបាញ់ថ្នាំ ឬសំអាតធុងបាញ់ថ្នាំនៅក្បែរប្រភពទឹក
- ត្រូវងូតទឹកជំរះដោយប្រើសាប៊ូក្រោយពេលលាយ និងបាញ់ថ្នាំកសិកម្ម
- រក្សាទុកថ្នាំកសិកម្មនៅកន្លែងស្ងួតត្រជាក់ល្មម និងបិទ ជិតមិនប៉ះពន្លឺថ្ងៃ និងភ្លើង
- រក្សាទុកថ្នាំកសិកម្មនៅក្នុងដប ឬ កញ្ចប់ដើមរបស់វានៅកន្លែងដែលមានសុវត្ថិភាព ផុតពីដៃក្មេង
- ដុត ឬកប់សំបកដប កញ្ចប់ថ្នាំ ដែលប្រើអស់នៅកន្លែងដែលឆ្ងាយពីប្រភពទឹក
- កុំប្រើប្រាស់សំបកដប កំប៉ុង ប៊ីដុងថ្នាំកសិកម្ម ឬ ឱ្យក្មេងលេងបន្ទាប់ពីប្រើថ្នាំអស់ ។



# វិធានការកំចាត់ពពួក ដង្កូវមេអំបៅ



